មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន

**រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥**

កាលពីឆ្នាំ២០១៣ សន្និបាតអង្គការសហប្រជាជាតិបានអនុម័ត និងប្រកាសយកថ្ងៃទី២ ខែវិច្ឆិកា ជាទិវាអន្តរជាតិ ដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន។ សេចក្តីសម្រេចនេះថ្កោលទោសគ្រប់ទម្រង់នៃការវាយប្រហារនិងការប្រើអំពើហិង្សាលើអ្នកសារព័ត៌មាន និងអ្នកធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងជំរុញរដ្ឋភាគីឱ្យអនុវត្តនូវវិធានការជាក់លាក់ប្រយុទ្ធប្រឆាំងលើវប្បធម៌និទណ្ឌភាព។ ទិវានេះជាការរម្លឹកស្មារតីដល់រដ្ឋជាភាគី ត្រូវចាត់វិធានការទប់ស្កាត់នូវរាល់អំពើហិង្សាលើអ្នកសារព័ត៌មាន និងអ្នកដែលធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងធានានូវគណនេយ្យភាព ដោយនាំជនល្មើសមកកាត់ទោស និងធានាថាជនរងគ្រោះទទួលបាននូវសំណងសមរម្យផងដែរ។ បន្ថែមលើនេះ ទិវានេះក៏អំពាវនាវដល់រដ្ឋជាភាគីក្នុងការលើកកម្ពស់នូវសុវត្ថិភាព និងបង្កបរិយាកាសដែលអ្នកសារព័ត៌មាន អាចបំពេញការងាររបស់ខ្លួនដោយឯករាជ្យ និងមិនមានការជ្រៀតជ្រែក។

ចាប់តាំងពីឆ្នាំ១៩៩៤មក យ៉ាងហោចណាស់មានអ្នកសារព័ត៌មានចំនួន ១៥នាក់ ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា ដោយសារការបំពេញការងាររបស់ខ្លួន ក្នុងនោះមានមួយករណីកើតឡើងនៅចុងឆ្នាំ២០២៤។ នៅក្នុងអំឡុងពេលនៃការស្លាប់នេះ ជនរងគ្រោះចំនួន១២នាក់ស្លាប់ដោយសារពាក់ព័ន្ធនឹងសកម្មភាពរាយការណ៍ព័ត៌មាន ដែលបានប៉ះពាល់ដល់បុគ្គលមានអំណាចនៅកម្ពុជា។ មកដល់បច្ចុប្បន្ននេះ ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យភាព និងតម្លាភាព មិនត្រូវបានដំណើរការ ដើម្បីនាំជនល្មើសដែលបានប្រព្រឹត្តិបទឧក្រិដ្ឋមកផ្តន្ទាទោសនៅឡើយទេ។ ករណីទាំងអស់នេះមិនត្រូវបានដោះស្រាយ ហើយជនរងគ្រោះមិនទាន់ទទួលបាននូវយុត្តិធម៌ ខណៈដែលជនល្មើសនៅតែបន្តរួចផុតពីការផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន។

**ចំពោះបញ្ហានេះ នាយកប្រតិបត្តិនៃ ម.ស.ម.ក លោក សេង សុវណ្ណនា មានប្រសាសន៍ថា៖**

«និទណ្ឌភាពមិនត្រឹមតែមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មប៉ុណ្ណោះទេ ប៉ុន្តែបញ្ហានេះក៏បង្កផលប៉ះពាល់ដោយផ្ទាល់ទៅលើសិទ្ធិដឹងឮរបស់សាធារណជនផងដែរ។ និទណ្ឌភាពចំពោះឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន គឺជាសារគំរាមកំហែងដល់អ្នកសារព័ត៌មាន និងបង្កើននូវការដាក់កំហិតសេរីភាពខ្លួនឯង។ រដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធត្រូវចាត់វិធានការប្រកបដោយអត្ថន័យ តម្លាភាព និងធ្វើការស៊ើបអង្កេតដោយឯករាជ្យ ដើម្បីនាំយកជនល្មើសមកទទួលខុសត្រូវចំពោះបទល្មើសរបស់ខ្លួន និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ។»

ដើម្បីប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មានឆ្នាំ២០២៥ ម.ស.ម.ក នឹងរៀបចំយុទ្ធនាការចាប់ពីថ្ងៃទី២៨ ខែតុលា ដល់ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥។ តាមរយៈសកម្មភាពយុទ្ធនាការនេះ ម.ស.ម.ក មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីតួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មាននៅក្នុងសង្គមប្រជាធិបតេយ្យ និងអំពើនិទណ្ឌភាពដែលបន្តមាននៅក្នុងប្រទេសកម្ពុជា រួមទាំងអំពើឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មានផងដែរ។ សូមចូលរួមជាមួយ ម.ស.ម.ក សម្រាប់ព្រឹត្តិការណ៍ដូចខាងក្រោម៖

- ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ ម.ស.ម.ក នឹងផ្សាយផ្ទាល់នូវកម្មវិធីវិទ្យុក្រោមប្រធានបទ«ការចងចាំ» ។
- ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ ម.ស.ម.ក នឹងផ្សាយឡើងវិញនូវវីដេអូរឿង «**អ្នកបន្តវេន**» ដែលរៀបរាប់ពីកូនប្រុសរបស់អ្នកសារព័ត៌មានម្នាក់ដែលត្រូវបានសម្លាប់ និងការព្យាយាមក្នុងការស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្លួន។
- ថ្ងៃទី៣១ ខែតុលា រហូតដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ម.ស.ម.ក នឹងចេញផ្សាយឡើងវិញនូវវីដេអូប្រវត្តិជនរងគ្រោះពីអំពើនិទណ្ឌភាពចំនួន១៥រូប ដែលជាអ្នកសារព័ត៌មាននិងអ្នកធ្វើការផ្នែកប្រព័ន្ធផ្សព្វផ្សាយ។
- ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ ម.ស.ម.ក នឹងផ្សាយប័ណ្ណព័ត៌មានស្ដីពីការរំលោភបំពានលើសេរីភាពសារព័ត៌មាន។
- ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ម.ស.ម.ក នឹងចេញផ្សាយនូវអត្ថបទវិភាគច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិក្នុងយុគសម័យឌីជីថល។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកអ្នកសម្របសម្រួលគម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា លោក ហួន ផន តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ ០៧០ ៧៥៧ ៨៨៤ ៕

<u>**ចប់**</u>

## បណ្ណាធិការ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS ៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។